## I-ខុទ្ទកាល័យព្រះមហាក្សត្រ

# ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ នស/រកត/១២/៩៧/២៧៣

## ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត /១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ និងពីរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្របតាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា១.**-មន្ត្រីរាជការស៊ីវិលទាំងអស់ត្រូវបានរៀបចំជាក្របខ័ណ្ឌ ដែលត្រូវបែងចែកជា ឋានន្តរស័ក្តិ ។ ក្របខ័ណ្ឌត្រូវចាត់ថ្នាក់ទៅតាមប្រភេទ ។

## ជំពូកទី ២

## អំពីប្រភេទ

**មាត្រា២.**-ក្របខ័ណ្ឌ មន្ត្រីរាជការស៊ីវិលទាំងអស់ ត្រូវបែងចែកជា ៤ប្រភេទ **ក.ខ.គ** និង **ឃ.** ដែលកំណត់ឡើងដោយយោងទៅតាមល័ក្ខខ័ណ្ឌ អប្បបរមា នៃការបណ្តុះបណ្តាលសំរាប់បញ្ចូលក្នុងក្របខ័ណ្ឌ និងកំរិតឋានានុក្រមនៃតំណែងរបស់ក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗ ចាំបាច់ត្រូវចាត់បញ្ចូលទៅក្នុងប្រភេទណាមួយនៃទាំង៤ តាមលក្ខន្តិកៈដោយឡែករបស់ខ្លួន ។

**មាត្រា៣.**-មន្ត្រីរាជការប្រភេទ **ក** មានមុខងារក្នុងតំណែង ដឹកនាំ អធិការកិច្ច សិក្សា និងផ្តល់យោបល់ និងមុខងារក្នុងរាល់តំណែងទទួលខុសត្រូវ ។ កំរិតអប្បបរមានៃការបណ្តុះបណ្តាល ដើម្បីអាចបញ្ចូលក្របខ័ណ្ឌក្នុងប្រភេទ **ក** គឺសញ្ញាបត្រមធ្យមសិក្សាកំរិត២ បូក៤ឆ្នាំ នៃការសិក្សា ដោយមានសញ្ញាបត្រ ។ លក្ខន្តិកៈដោយឡែកខ្លះអាចប្រសិនបើចាំបាច់ តម្រូវនូវកំរិតអប្បបរមានៃការបណ្តុះបណ្តាលស្មើ ឬលើសសញ្ញាបត្រមធ្យមសិក្សាកំរិត២ បូក៦ឆ្នាំ នៃការសិក្សាដោយមានសញ្ញាបត្រ ។ ក្នុងករណីនេះ ត្រូវមានផ្តល់នូវការបន្ថែមសន្ទស្សន៍បៀវត្ស ។

**មាត្រា៤.–** ប្រភេទ ខ មានមុខងារក្នុងការរៀបចំការងារ សំរាប់អ្នកទទួលខុសត្រូវសំរេច និងដាក់ អោយអនុវត្ត ។ កំរិតអប្បបរមា ដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ ខ គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ បូក២ឆ្នាំ នៃការសិក្សាដោយមានសញ្ញាបត្រ ។

**មាត្រា៥.–** ប្រភេទ គ មានមុខងារក្នុង លេខាធិការដ្ឋាន និង មុខងារប្រតិបត្តិដែលតម្រូវអោយមានចំណេះបច្ចេកទេស ឬចំណេះធ្វើការងារ ។ កំរិតអប្បបរមា ដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ គៈ គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ។

**មាត្រា៦.–** ប្រភេទ ឃ មានមុខងារក្នុងការប្រតិបត្តិ ។ ការបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទនេះ ពុំតម្រូវអោយមានលក្ខខ័ណ្ឌអំពីសញ្ញាប័ត្រឡើយ ។

**មាត្រា៧.–** កំរិតអប្បបរមានៃការបណ្តុះបណ្តាលដែលបានកំណត់ក្នុងមាត្រា ៣.៤.និង ៥. នៃព្រះរាជក្រឹត្យនេះ ត្រូវអនុវត្តចំពោះនិស្សិតទាំងឡាយណា ដែលត្រូវបានជ្រើសរើសអោយចូលមុខងារសាធារណៈ តាមការប្រឡងប្រជែង ចាប់ពីថ្ងៃផ្សព្វផ្សាយព្រះរាជក្រឹត្យនេះ ។

**មាត្រា៨.–** មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញភារកិច្ចក្នុងមុខតំណែង តាមការតែងតាំងដែលមានរួចហើយ ត្រូវផ្ទេរបញ្ចូលក្នុងក្របខ័ណ្ឌថ្មី ។ គណៈកម្មការអន្តរក្រសួងមួយនឹងត្រូវបានតែងតាំងដោយអនុក្រឹត្យ ដើម្បីលើកគោលការណ៍សំរាប់ការចាត់ថ្នាក់ថ្មីជូនរាជរដ្ឋាភិបាលពិនិត្យនិងសំរេច ។

## ជំពូកទី ៣

## អំពីក្របខ័ណ្ឌ

**មាត្រា៩.–** ក្របខ័ណ្ឌនីមួយៗ នៃមន្ត្រីរាជការ គឺជាការប្រមូលផ្តុំភ្នាក់ងារ ដែលមានគុណសម្បត្តិ ឬការបណ្តុះបណ្តាលដូចគ្នា ហើយដែលមានឧបនិស្ស័យកាន់តំណែងដូចគ្នា ឬប្រភេទមុខតំណែងដូចគ្នា ក្នុងអាជីពរបស់ខ្លួននៅក្នុងក្រសួងណាមួយ ។

**មាត្រា១០.–** ក្របខ័ណ្ឌនីមួយៗ ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកមួយដែលរៀបចំដោយក្រសួងសាមី និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ លក្ខន្តិកៈដោយឡែកត្រូវកំណត់ឡើងដោយព្រះរាជក្រឹត្យ និងដោយមានការយល់ព្រមពីគណៈកម្មាធិការ

ប្រតិបត្តិនៃគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាល និងពីក្រុមប្រឹក្សាអ្នកច្បាប់ ។

**មាត្រា១១.**– លក្ខន្តិកៈដោយឡែកបង្កើតក្របខ័ណ្ឌនីមួយៗ និង រៀបចំអាជីព ត្រូវស្របទៅតាមបទបញ្ញត្តិសហលក្ខន្តិកៈ នៃមន្ត្រីរាជការស៊ីវិល និង តាមអត្ថបទថ្មីនេះ ។ លក្ខន្តិកៈដោយឡែក ត្រូវមានជាចាំបាច់នូវបទបញ្ញត្តិដូចតទៅ :

ក– ការភ្ជាប់ក្របខ័ណ្ឌក្នុងក្រសួងមួយ

ខ– ការចាត់ថ្នាក់ក្របខ័ណ្ឌទៅក្នុងប្រភេទមួយ

គ– ការកំណត់បេសកកម្មទូទៅរបស់ក្របខ័ណ្ឌ

ឃ– ការកំណត់មុខតំណែង ដែលភ្នាក់ងារក្របខ័ណ្ឌត្រូវបំពេញ

ង– ការកំណត់លក្ខណៈសម្បត្តិអប្បបរមា ដើម្បីបញ្ចូលក្នុងក្របខ័ណ្ឌ និងបែបបទនៃការប្រឡងប្រជែងផ្ទៃក្នុងនិងការប្រឡងប្រជែងចូលក្របខ័ណ្ឌរាជការ ដោយនិស្សិតសុទ្ធសាធ

ច– របបកម្មសិក្សាសាកល្បង

ឆ– ការកំណត់ឋានានុក្រមក្របខ័ណ្ឌ (បែងចែកក្របខ័ណ្ឌជាឋានន្តរស័ក្តិ និង កំណត់មុខតំណែងសំរាប់ឋានន្តរស័ក្តិនីមួយៗ )

ជ– វិធានសំរាប់តម្លើងថ្នាក់ និង តម្លើងឋានន្តរស័ក្តិ ។

**មាត្រា១២.**– អនុក្រឹត្យមួយ នឹងកំណត់ខ្លឹមសារគំរូនៃលក្ខន្តិកៈដោយឡែក និងវិធីអនុវត្ត ដើម្បីបង្កើតក្របខ័ណ្ឌ ។

## ជំពូកទី ៤
## អំពីឋានន្តរស័ក្តិ

**មាត្រា១៣.**– ឋានន្តរស័ក្តិ គឺជាលំដាប់ឋានានុក្រមនៃក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗចាំបាច់ ត្រូវបែងចែកជា ៣ ឋានន្តរស័ក្តិ ឋានានុក្រម ។ ឋានន្តរស័ក្តិនីមួយៗ ឆ្លើយតបទៅនឹងមុខតំណែង ឬ សារព័ន្ធមុខតំណែង ដែលមានការទទួលខុសត្រូវកាន់តែខ្ពស់ ។

**មាត្រា១៤.**– និស្សិតដែលមិនមែនជាមន្ត្រីរាជការ ហើយដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងអោយចូលក្នុងមុខងារសាធារណៈ ចាំបាច់ត្រូវតាំងស៊ប់ក្នុងឋានន្តរស័ក្តិដំបូងនៃក្របខ័ណ្ឌ ។

**មាត្រា១៥.**– ជាធម្មតា ភ្នាក់ងារទាំងឡាយអាចមានឧបនិស្ស័យ សំរាប់ដំណើរការអាជីពរហូតក្នុងវិជ្ជាជីវៈរបស់ខ្លួនក្នុងឋានន្តរស័ក្តិដំបូង ដោយមានការតម្លើងថ្នាក់ជាទៀងទាត់ ទៅតាមបទបញ្ញត្តិនៃសហលក្ខន្តិកៈ និង លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌរបស់ខ្លួន ។

**មាត្រា១៦.**– ការតម្លើងឋានន្តរស័ក្តិ ក្នុងឋានន្តរស័ក្តិទី២ ទី៣ គឺសំរាប់ភ្នាក់ងារណាដែលមានគុណសម្បត្តិជាងគេ ។ ការតម្លើងឋានន្តរស័ក្តិនេះផ្អែកទៅលើភាពទំនេរនៃតំណែង ហើយប្រព្រឹត្តទៅតាមការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមការទទួលបាននូវវិញ្ញាបនបត្រសិក្សារយៈពេលវែង នៅសាលាភូមិន្ទរដ្ឋបាល ឬសាលាអនុវត្តដែលទទួលស្គាល់ដោយលក្ខន្តិកៈដោយឡែក ឬតាមការប្រឡងប្រជែង ។ អាចត្រូវបានតម្លើងឋានន្តរស័ក្តិទី២ នៃក្របខ័ណ្ឌមួយ ចំពោះភ្នាក់ងារទាំងឡាយណាដែលបានឡើងដល់ថ្នាក់ទី៤ នៃឋានន្តរស័ក្តិដំបូងរួចហើយ ។ អាចត្រូវបានតម្លើងទៅឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមួយ ចំពោះភ្នាក់ងារទាំងឡាយណាដែលបានឡើងដល់ថ្នាក់ទី៤ នៃឋានន្តរស័ក្តិ ទី ២ រួចហើយ ។ ការឡើងឋានន្តរស័ក្តិ ទៅឋានន្តរស័ក្តិខ្ពស់ជាងមួយទៀត ផ្តល់ឧបនិស្ស័យដល់សាមីជន ដើម្បីទទួលមុខតំណែងស្របទៅតាម ឋានន្តរស័ក្តិថ្មី ដូចដែលបានកំណត់ក្នុងលក្ខន្តិកៈដោយ ឡែក ។

**មាត្រា១៧.**– បែបបទនៃការដាក់ចំនួនភ្នាក់ងារបច្ចុប្បន្នបញ្ចូលក្នុងឋានន្តរស័ក្តិថ្មីនៃក្របខ័ណ្ឌ និងអន្តរប្បញ្ញត្តិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥

## អំពីថ្នាក់

**មាត្រា១៨.**– ឋានន្តរស័ក្តិនីមួយៗ ត្រូវបានបែងចែកជាថ្នាក់ ដែលមានសន្ទស្សន៍កំណត់ អំពីកំរិតលាភការ ។

**មាត្រា១៩.**– ឋានន្តរស័ក្តិ ទី១ ត្រូវបានចែកចេញជា ១៤ ថ្នាក់ ។ ឋានន្តរស័ក្តិ ទី២ ចែកចេញជា ១០ ថ្នាក់ ។ ឋានន្តរស័ក្តិ ទី៣ ចែកចេញជា ៦ ថ្នាក់ ។

**មាត្រា២០.**– ជាធម្មតា មន្ត្រីរាជការទាំងអស់ ត្រូវបានតម្លើងថ្នាក់ក្នុង២ឆ្នាំម្តង វៀរលែងក្នុងករណីដែលត្រូវបានផ្តល់អត្ថប្រយោជន៍ ស្តីពីអតីតភាព ដែលជាលទ្ធផលចេញមកពីស្នាដៃពិសេស ឬបើជាការចាំបាច់ពីភាពលំបាកពីកំរិតនៃការទទួលខុសត្រូវ ឬពី

លក្ខណៈស្ថិតក្នុងតំបន់ជាប់ស្រយាលនៃមុខតំណែងខ្លះ ។ លក្ខន្តិកៈដោយឡែកត្រូវកំណត់ព្រំដែនជាក់លាក់នៃមុខតំណែង ដែលអាចផ្តល់អត្ថប្រយោជន៍លើអតីតភាពថ្នាក់ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា២១.–** នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា២២.–** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

***